## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា
## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបិទ
## កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៣
## នៅអគារមិត្តភាព ទីស្តីការគណៈរដ្ឋមន្ត្រី
## ថ្ងៃព្រហស្បតិ៍ ១២ រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧
## ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣

ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលកំពុងមានវត្តមានដ៏មានតម្លៃក្នុងកិច្ចប្រជុំនាពេលនេះ!

ឆ្លងកាត់នូវការចំណាយពេលដ៏មានតម្លៃពេញមួយព្រឹក កិច្ចប្រជុំពេញអង្គរបស់យើងបានធ្វើបទបង្ហាញ រួមជាមួយនឹងការពិភាក្សា និងផ្តល់យោបល់យ៉ាងផុលផុស ដែលនាំឱ្យយើងទទួលបាននូវលទ្ធផលគួរជាទីមោទនៈសមស្របទៅនឹងកម្មវត្ថុនៃកិច្ចប្រជុំនាពេលនេះ ដែលខ្ញុំសូមសង្ខេបជូនដូចតទៅ ៖

**ទី១ :** ការអនុម័តជាគោលការណ៍នូវរបាយការណ៍វឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធផលក្នុងការឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ រយៈពេល៦ខែដើមឆ្នាំ២០២៣។

**ទី២ :** ការបន្តជំរុញឱ្យមានវឌ្ឍនភាព និងការបន្តការអនុវត្ត "សេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីវិធានការទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

**ទី៣ :** ការអនុម័ត សេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៣ សម្រាប់បន្តអនុវត្តក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឆ្ពោះទៅសម្រេចបាននូវគោលដៅ ៩៥-៩៥-៩៥ នាឆ្នាំ២០២៥។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!***

ទោះបីជាពេលវេលារបស់យើងមានពេលមួយព្រឹកក៏ពិតមែន តែដោយសារមានការចូលរួមយ៉ាងសកម្មពី ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា បានធ្វើឱ្យពេលវេលាដ៏មានតម្លៃរបស់យើងអាចទទួលបាននូវផ្លែផ្កា ដែលខ្ញុំសូមយកឱកាសនេះ សម្តែងនូវការកោតសរសើរដ៏ស្មោះបំផុត ជូនសមាជិក សមាជិកានៃអង្គពិធីទាំងមូល។ សម្រាប់កម្មវិធីអេដស៍ឆ្នាំ២០២៤-២០២៦ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចផ្តល់ថវិកា១៥លានដុល្លារអាមេរិកសម្រាប់ទិញឱសថព្យាបាល។ ក្រៅពីនេះគម្រោង PEPFAR របស់សហរដ្ឋអាមេរិក ក៏នឹងចំណាយថវិកាប្រមាណ១១,៨លានដុល្លារអាមេរិកក្នុងកម្មវិធីអេដស៍ដែរ។ នៅឆ្នាំ២០២៣ រាជរដ្ឋាភិបាលក៏បានវិភាជន៍ថវិកាចំនួន៦០លានរៀលក្នុងមួយឆ្នាំក្នុងមួយខេត្ត ដល់ខេត្តចំនួន១១ និងនៅឆ្នាំ២០២៤ រាជរដ្ឋាភិបាលក៏បានគ្រោងវិភាជថវិកាចំនួន៤០លានរៀលក្នុងមួយឆ្នាំក្នុងមួយខេត្ត ដល់ខេត្តចំនួន១០ ចុងក្រោយទៀត។ ជាសរុប ចាប់ពីឆ្នាំ២០២២ ដើម្បីជំរុញការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបាន និងគ្រោងវិភាជន៍ថវិកាចំនួន១.៣៨០លានរៀលក្នុងមួយឆ្នាំ ដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្តទាំង២៥ សម្រាប់កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ។

ខ្ញុំសូមអនុញ្ញាតឆ្លៀតឱកាសមុនបិទកិច្ចប្រជុំពេញអង្គរបស់យើង ផ្តល់ជូននូវចំណាប់អារម្មណ៍បូកសរុបលទ្ធផលជារួមដែលទទួលបានពីកិច្ចប្រជុំនេះដូចខាងក្រោម ៖

១) ជារួម យើងទាំងអស់គ្នាពិតជាបានខិតខំអនុវត្តផែនការសកម្មភាព រយៈពេល៦ខែដើមឆ្នាំ២០២៣ ទៅតាមក្រសួង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ សង្គមស៊ីវិល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

២) សូមអបអរសាទរចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័នពាក់ព័ន្ធ ដែលបានចូលរួម និងផ្តួចផ្តើមឱ្យមានកិច្ចប្រជុំនានា ដើម្បីឆ្លើយតបនឹង "សេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីវិធានការទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដែលមកទល់ពេលនេះ បានសម្របសម្រួលដល់ការផ្តល់ និងប្រើប្រាស់កញ្ចប់ថវិកាជាតិ ក្នុងការងារប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់បណ្តាខេត្តដែលមានហានិភ័យផ្សេងទៀត ។

៣) សូមលើកទឹកចិត្តជូនគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្ត ឱ្យបន្តជំរុញ និងចូលរួមសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសអាជ្ញាធរឃុំ សង្កាត់ ក្នុងការអនុវត្ត "សេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ។

៤) បន្តសហការជាមួយស្ថាប័នពាក់ព័ន្ធ ជាពិសេសជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីបន្តសិក្សាលើលទ្ធភាពប្រើប្រាស់ អត្ថប្រយោជន៍គាំពារ សង្គម ក្នុងការគាំទ្រដល់ការងារឆ្លើយតបនឹងការរាលដាលមេរោគអេដស៍ ជាពិសេស ក្នុងការលើកទឹកចិត្តឱ្យប្រជាជនគន្លឹះស្ម័គ្រចិត្តមកធ្វើតេស្តឈាមរកមេរោគអេដស៍។ កិច្ចអន្តរាគមន៍គាំពារសង្គមដល់ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះ អាចចាត់ទុកជាមធ្យោបាយមួយ ក្នុងការបង្កើនការមកទទួលយកសេវាសុខភាព ក្នុងនោះរួមទាំងការធ្វើតេស្តឈាមរកមេរោគអេដស៍ សម្រាប់ក្រុមប្រជាជនគន្លឹះផង។

ជាមួយគ្នានេះផងដែរ ខ្ញុំសូមផ្តល់ជូននូវអនុសាសន៍មួយចំនួនដូចខាងក្រោម ៖

១) អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវប្រមូលរាល់អនុសាសន៍ទាំងអស់ដែលបានអនុម័តជាគោលការណ៍នៅក្នុងកិច្ចប្រជុំនេះ ដើម្បីយកទៅរៀបចំ និងកែលម្អសម្រាប់ដាក់ចេញនូវគម្រោងផែនការសកម្មភាពនាពេលខាងមុខ។

២) ជំរុញ និងប្រើប្រាស់គ្រប់យន្តការទាំងអស់ ដើម្បីធ្វើឱ្យសម្រេចបានជោគជ័យក្នុងការអនុវត្ត "សេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីវិធានការទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

៣) ប្រឹងប្រែងអនុវត្តសេចក្តីសម្រេចចិត្តនៃសម័យប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២២ ដែលទើបបានទទួលការអនុម័តនាពេលនេះ។

៤) បន្តជំរុញ និងលើកទឹកចិត្តក្រសួង ស្ថាប័ន ដែលពុំទាន់បានទទួលថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យលើកសំណើថវិកាឆ្នាំ២០២៣ ក្នុងកញ្ចប់នៃផែនការថវិការបស់ក្រសួង ស្ថាប័នសាមីឱ្យបានព្រមៗគ្នា។

៥) បន្តជំរុញការអនុវត្ត រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីសម្រេចឱ្យបានជោគជ័យនូវ ***កម្មវិធីគំនិតផ្តួចផ្តើមទីក្រុងរួមគ្នាពន្លឿនការឆ្លើយតបការរីករាលដាលជំងឺអេដស៍*** (Fast-Track Cities Initiative) ដែលបាន និងកំពុងដំណើរការ នៅក្នុងទីក្រុងភ្នំពេញ ខេត្តបាត់ដំបង សៀមរាប និងបន្ទាយមានជ័យ។

៦) លើកទឹកចិត្តជូនខេត្តចំនួន១១ បន្ថែមទៀត ឱ្យរៀបចំផែនការសកម្មភាព និងថវិកាឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

៧) សូមលើកទឹកចិត្តជូនក្រសួងផែនការ ក្រសួងសុខាភិបាល និង មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បន្តធ្វើការសហការជំរុញផ្តល់ប័ណ្ណក្រីក្រ ដល់អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ជាបុគ្គល នៅតាម ART sites ឱ្យបានកាន់តែច្រើនបន្ថែមទៀត។

៨) បន្តរុករកអ្នកដែលមិនទាន់បានមកទទួលសេវា ឱ្យមកទទួលយកសេវា បង្កើនការគ្របដណ្តប់ និងផ្តល់អន្តរាគមន៍ឱ្យមានប្រសិទ្ធិភាព ទៅលើក្រុមប្រឈម ពិសេសក្រុមបុរស

រួមភេទជាមួយបុរស ក្រុមបំប្លែងភេទ ដោយបង្កើនតំបន់គ្របដណ្តប់កម្មវិធី PrEP ឱ្យបានទូលំទូលាយ និងកាន់តែមានប្រសិទ្ធភាព។

៩) បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីទទួលបានជំនួយទាំងសម្ភារ ថវិកា និងបច្ចេកទេស សម្រាប់បន្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជាទៅមុខទៀត រហូតសម្រេចបានជោគជ័យក្នុងការលុបបំបាត់ជំងឺអេដស៍ជាស្ថាពរ ជាពិសេសគ្រប់គ្រងឱ្យបានទាំងស្រុងក្រុមប្រជាជនគន្លឹះ ដែលតម្រូវឱ្យមានកម្មវិធីឆ្លើយតបប្រកបដោយប្រសិទ្ធភាពខ្ពស់ ដូចដែលយើងបានធ្វើចំពោះ*ក្រុមនារីបម្រើសេវាកម្សាន្តសប្បាយ*នៅតាមគ្រឹះស្ថាននានាផងដែរ។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!***

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំពេញអង្គដ៏មានសារៈសំខាន់នាពេលនេះ។ តាមរយៈការចូលរួមយ៉ាងសកម្ម ដោយផ្តល់នូវគំនិត យោបល់ល្អៗ និងមានតម្លៃ នាំឱ្យយើងអាចយកទៅប្រើប្រាស់ក្នុងការកែលម្អការអនុវត្តការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឱ្យកាន់តែមានប្រសិទ្ធភាពថែមមួយកម្រិតទៀត។

ខ្ញុំសូមសម្តែងនូវការកោតសរសើរផងដែរចំពោះ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានខិតខំរៀបចំកិច្ចប្រជុំពេញអង្គនេះ ឱ្យប្រព្រឹត្តទៅបានដោយរលូន និងសម្រេចបាននូវលទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈនាពេលនេះ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់នូវពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ និងធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

ខ្ញុំសូមប្រកាសបិទ “**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៣**” ចាប់ពីពេលនេះតទៅ។

***សូមអរគុណ!***